# របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ

# ក្រោមប្រធានបទ «ចាញ់បានជាព្រះ ឈ្នះបានជាមារ» តើពាក្យនេះអាចជាឧបសគ្គក្នុងការថែរក្សាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីឬទេ ?

**Website: www.hoksavann.org**

ថ្ងៃទី១ ឧសភា ២០១០



ពាក្យថា «ចាញ់បានជាព្រះ ឈ្នះបានជាមារ» ជាពាក្យកើតចេញមកពីអ្នកកាន់ព្រះពុទ្ធសាសនាពោលឡើងនៅពេលដែលមានមនុស្សទាស់ទែងខ្វែងគំនិតគ្នា ឲ្យចេះអត់ឱនគ្នា កុំប្រើអំពើហឹង្សា ។ សុខចិត្តចាញ់ឲ្យគេឈ្នះទៅចុះ ចាញ់នឹងបានជាព្រះ ឯអ្នកឈ្នះនឹងបានជាមារ ។

ពាក្យថា «ចាញ់បានជាព្រះ» គឺចាញ់ក្នុងន័យថា ពុំប្រព្រឹត្តធ្វើអំពើអាក្រក់ ខុសច្បាប់ផ្លូវធម៌និងខុសច្បាប់សង្គម ដូចជាជនពាល ។ ពាក្យថាព្រះនេះ បើសំដៅយកព្រះពុទ្ធត្រាស់ដឹង គឺព្រះអង្គលះបង់នូវគ្រឿងសៅហ្មងក្នុងព្រះទ័យរបស់ព្រះអង្គ ដែលជាហេតុនាំឲ្យសាងបាបកម្មអស់ហើយ ទើបបានត្រាស់ជាព្រះពុទ្ធ ។ ព្រះអង្គមានព្រះទ័យបរិសុទ្ធ ពុំមានធូលីគឺកិលេសតណ្ហាដូចមានព្រះនាមក្នុងពុទ្ធគុណថា អរហំ ប្រែថា ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ។ ព្រះអង្គលះបង់កិលេសតណ្ហានេះអស់ហើយ ទើបព្រះអង្គឈ្នះមារ បានត្រាស់ជាព្រះពុទ្ធ ។

ពាក្យថា «មារ» បើពោលជាធម្មាធិដ្ឋានបានដល់សភាវៈសម្លាប់ សភាវៈបៀតបៀនបង្អាក់ដំណើរមិនឲ្យមនុស្សសត្វបានសេចក្តីសុខ ។ បើពោលជាបុគ្គលធិដ្ឋាន បានដល់បុគ្គលដែលបៀតបៀនបុគ្គលដទៃ មិនឲ្យគេបានសេចក្តីសុខ ។ ក្នុងព្រះពុទ្ធសាសនាមារមាន៥យ៉ាងគឺ ៖ ខន្ធមារ មារគឺខន្ធ៥ គឺរូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ។ កិលេសមារ មារគឺកិលេសបានដល់លោភៈ ទោសៈ មោហៈ ។ មច្ចុមារ មារគឺសេចក្តីស្លាប់ ។ អភិសង្ខារមារ មារគឺអភិសង្ខារបានដល់បុណ្យបាប ។ ទេវបុត្តមារ មារគឺទេវបុត្តបានដល់សង្កិលេស ។ ព្រះអង្គឈ្នះមារទាំង៥នេះ ទើបឆ្លងផុតពីសេចក្តីទុក្ខក្នុងវដ្តសង្សារ ។ ពាក្យខ្មែរក៏បានពោលថា ចាញ់ដើម្បីឈ្នះ គឺចាញ់មិនសាងអាក្រក់ តែនឹងបានទទួលជ័យជំនះដោយសារអំពើល្អរបស់ខ្លួន ។

ពាក្យថា «ឈ្នះបានជាមារ» បើនិយាយពីមារមានរូប បានដល់បុគ្គលពាលដែលតែងតែប្រព្រឹត្តធ្វើអំពើអាក្រក់ តាមព្យាបាទបៀតបៀនអ្នកដទៃ ធ្វើឲ្យគេមានទុក្ខ ។ មារដែលព្រះពុទ្ធបានឈ្នះ គឺមារដែលស្ថិតនៅក្នុងព្រះទ័យព្រះអង្គ មានលោភៈ ទោសៈ មោហៈជាដើម ។ បានជាលោកចាត់កិលេសតណ្ហានេះជាមារ ព្រោះកិលេសតណ្ហានេះជាហេតុជាបច្ច័យបិទបាំង ឬជាអន្ទាក់មិនឲ្យព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធបាន ។ គេចាត់ទុកមនុស្សនិងប្រទេសដែលបៀតបៀននិងឈ្លានពានគេជាមារ ព្រោះធ្វើឲ្យមនុស្សនិងប្រទេសដទៃមានទុក្ខ ដោយការរំលោភឈ្លានពានរបស់ខ្លួន ។ បុគ្គលដែលជាមារនេះ ពេលខ្លះបានទទួលជ័យជំនះក្នុងរយៈពេលខ្លី ទីបំផុតត្រូវទទួលបរាជ័យវិញ ។ ប្រទេសនានាក្នុងពិភពលោកនិងអង្គការសហប្រជាជាតិតែងបញ្ញត្តិច្បាប់រៀងៗខ្លួន ដើម្បីកំចាត់មនុស្សជាមារនេះ ។ បើនិយាយតាមភាសាមនុស្សលោកសព្វថ្ងៃនេះ មនុស្សមារគឺមនុស្សរំលោភសិទ្ធិមនុស្សនេះឯង ។ ការលួចកាប់សម្លាប់ ការលួចប្លន់ ការរំលោភបៀតបៀនគ្រប់បែបយ៉ាង ដែលជាអំពើរបស់ជនសាមញ្ញក្តី របស់អ្នកនយោបាយក្តី សុទ្ធសឹងជាអំពើពាល ចាត់ចូលជាបក្សពួកមារ ព្រោះបៀតបៀនធ្វើឲ្យសង្គមមានទុក្ខ ។ ធម្មជាតិរបស់មារ ទោះមានរូបក្តីឥតរូបក្តី តែងបញ្ចេញអំពើអាក្រក់របស់ខ្លួន តែទីបំផុតត្រូវបរាជ័យនិងបាត់បង់ទៅវិញ ដូចពុទ្ធភាសិតថា ឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ ។ ព្រះពុទ្ធជាតំណាងសេចក្តីល្អ ឯមារជាតំណាងសេចក្តីអា-ក្រក់ ។ ព្រះពុទ្ធជាបុគ្គលឈ្នះមារ ឯមារត្រូវទទួលបរាជ័យដោយអំពើអាក្រក់របស់ខ្លួន ។

ពាក្យថា «ចាញ់បានជាព្រះ ឈ្នះបានជាមារ» នេះ ពុំមានឧបសគ្គក្នុងការថែរក្សាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីខ្មែរទេ ព្រោះសព្វថ្ងៃនេះពិភពលោកមានច្បាប់ គ្រប់ប្រទេសទាំងអស់ត្រូវគោរពច្បាប់ បើប្រទេសណាមួយរំលោភលើប្រទេសមួយទៀតជាសមាជិក ជាអំពើខុសច្បាប់ ។ ប្រទេសដែលត្រូវគេឈ្លានពាននោះ មានសិទ្ធិស្របច្បាប់ក្នុងការការពារប្រទេសរបស់ខ្លួន ដោយមធ្យោបាយផ្សេងៗ ហើយអាចប្តឹងដល់អង្គការសហប្រជាជាតិឲ្យគេជួយធ្វើអន្តរាគមន៍ផង ។ ពាក្យថា «បាញ់បានជាព្រះ ឈ្នះបានជាមារ» ពុំមែនមានន័យថា ប្រទេសណាមួយឈ្លានពានប្រទេសកម្ពុជា ត្រូវអ្នកដឹកនាំខ្មែរនិងពលរដ្ឋខ្មែរឱបដៃមើល បណ្តោយឲ្យបរទេសឈ្លានពានតាមអំពើចិត្តនោះឡើយ ផ្ទុយទៅវិញត្រូវអ្នកដឹកនាំនិងពលរដ្ឋខ្មែរសាមគ្គីគ្នាប្រឆាំងនឹងការឈ្លានពាននេះ ដើម្បីការពារអ្វីៗទាំងអស់របស់ខ្មែរ មានទឹកដីជាដើម ទោះបីប្រើសន្តិវិធីក្តី យុទ្ធវិធីក្តី ជាអំពើស្របច្បាប់ ជាសិទ្ធិការពារខ្លួនពីប្រទេសរំលោភដែលជាមារ មិនទាស់ខុសនឹងប្រធានបទខាងលើនេះឡើយ ។ តាមព្រះពុទ្ធសាសនា ដំណោះស្រាយគ្រប់បញ្ហាទំនាស់ទាំងអស់ បើអាចប្រើសន្តិវិធីបានជាការប្រពៃណាស់ ព្រោះថាការប្រើយុទ្ធវិធីទាំងអ្នកចាញ់ទាំងអ្នកឈ្នះតែងតែខូចខាតទាំងទ្រព្យសម្បត្តិ ទាំងជីវិតមនុស្ស ។ ការប្រើសន្តិវិធីតាមផ្លូវច្បាប់ អាចធ្វើឲ្យភាគីទាំងអ្នកចាញ់និងអ្នកឈ្នះមិនខូចខាត ហើយធ្វើឲ្យភាគីទាំងសងខាងសុខចិត្តទាំងអស់គ្នា ។ ជំនះប្រកបដោយយុត្តិធម៌ជាជំនះប្រសើថ្លៃថ្លា ។៚

❇ ❇

❇